**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ.......១០២.........បទ..ស.ស.រ............

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ចជូនទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្កកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩២៧ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១១២១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៧៨ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/២០២ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ .-**

ប្រគល់ភារកិច្ចជូនទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម ៖

កាច់ជ្រុងវិថីលេខ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៤២៧៦
ទូរសារ (៨៥៥) ២៣-៤២៦៥៩១/៤២៦០០៥/៧២៤៨០៩

១ - ឯកឧត្តម **ឡុង វ៉ានហាន** ជំនួយការជួយរដ្ឋមន្ត្រី លើការងារច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធវិស័យប្រៃសណីយ៍។

២ - ឯកឧត្តម **គួច គី** ជំនួយការជួយរដ្ឋមន្ត្រី លើការងារគោលនយោបាយប្រៃសណីយ៍។

៣ - ឯកឧត្តម **ញាន ស្រស់** ជំនួយការជួយរដ្ឋមន្ត្រី លើការងាររដ្ឋបាល ។

៤ - ឯកឧត្តម **សៅ ខិន** ជំនួយការជួយរដ្ឋមន្ត្រីលើការងារគោលនយោបាយប្រៃសណីយ៍ ។

៥ - លោកជំទាវ **លិម លឿន** ជំនួយការជួយរដ្ឋមន្ត្រី លើការងារត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ ។

៦ - ឯកឧត្តម **ឡាយ សំអុល** ជំនួយការជួយ រដ្ឋមន្ត្រី ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី។

៧ - ឯកឧត្តម **ខេង សិទ្ធិគុណា** ជំនួយការជួយ រដ្ឋមន្ត្រី លើការងារខុទ្ទកាល័យរដ្ឋមន្ត្រី។

៨ - ឯកឧត្តម **គិម ថិត្រា** ជំនួយការជួយ រដ្ឋមន្ត្រី លើការងារទូរគមនាគមន៍កម្ពុជា។

៩ - ឯកឧត្តម **អៀង ស្រេង** ជំនួយការជួយ រដ្ឋមន្ត្រី លើការងារសហប្រតិបត្តិការអន្តរជាតិ។

១០ - ឯកឧត្តម **លី ភាយឫទ្ធិ** ជំនួយការជួយ រដ្ឋមន្ត្រី លើការងារសំណង់-អគារ ។

**ប្រការ ២ .-**

សាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ អាចទទួលការងារបន្ថែមមួយចំនួនទៀតតាមការចាំបាច់ ដែលរដ្ឋមន្ត្រីប្រគល់ជូន និងត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ និងសេចក្តីសម្រេចលេខ ១០១ បទ.សសរ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ៣ .-**

សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ .-**

សេចក្តីសម្រេចនេះ នឹងត្រូវបានកែសម្រួលក្នុងករណីចាំបាច់ ។

**ប្រការ ៥ .-**

គ្រប់ថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកដ្ឋាន វិទ្យាស្ថានជាតិ អគ្គាធិការដ្ឋាន នាយកដ្ឋាន មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ប្រាក់ សុខុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង - ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

" **ដើម្បីជូនជ្រាប** "

- ដូចប្រការ៥ " **ដើម្បីអនុវត្ត** "
- ឯកសារ - កាលប្បវត្តិ